**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារលិខិតរំលែកទុក្ខ

## គោរពជូន

## ក្រុមគ្រួសារនិងញាតិមិត្តនៃសពឯកឧត្តម សាយ ភូថង

## សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំ ភរិយាខ្ញុំនិងក្រុមគ្រួសារ មានទុក្ខក្រៀមក្រំនិងក្តីរន្ធត់ក្តុកក្តួលក្នុងចិត្តយ៉ាងក្រៃលែង ចំពោះមរណភាពរបស់ ឯកឧត្តម **សាយ ភូថង** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាអតីត អនុប្រធានក្រុមប្រឹក្សារដ្ឋ (អនុប្រធានរដ្ឋ ) ដែលបានទទួលមរណភាពនៅវេលាម៉ោង ៥: ០៦នាទី ល្ងាច ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦នៅក្នុងមន្ទីរពេទ្យនាទីក្រុងបាងកក ប្រទេសថៃ ក្នុងជន្មាយុ ៩៦ ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសដ៏សោកសង្រេងនេះ យើងខ្ញុំទាំងអស់គ្នា សូមចូលរួមមរណទុក្ខ យ៉ាងក្រៀមក្រំបំផុតជាមួយក្រុមគ្រួសារនិងញាតិមិត្តនៃសព ឯកឧត្តម **សាយ ភូថង** ប្រកបដោយសមានទុក្ខនិងក្តីសង្វេគទុក្ខជាទីបំផុត។

មរណភាពរបស់ឯកឧត្តម **សាយ ភូថង** គឺជាការបាត់បង់នូវស្ថាបនិកដ៏ឆ្នើមរបស់គណបក្សប្រជាជនកម្ពុជា និងជាឥស្សរៈជនដឹកនាំដ៏ឆ្នើមមួយរូប ដែលបានលះបង់និងធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិនិងប្រជាជន ជាពិសេសក្នុងការចូលរួមរំដោះប្រទេសជាតិពីរបបខ្មែរក្រហម។

គំរូវីរភាពដ៏ល្អប្រពៃរបស់ឯកឧត្តមបានស្ថិតនៅជានិច្ចក្នុងមនសិការរបស់ប្រជាជនកម្ពុជា ហើយរូបកាយរបស់ឯកឧត្តម បានបាត់បង់ក៏ពិតមែន តែកិត្តិយស គុណបំណាច់ កេរ្តិ៍ឈ្មោះ ស្នាដៃនិងឧត្តមគតិរបស់ឯកឧត្តម បានដក់ជាប់នៅក្នុងក្រអៅបេះដូងយើងខ្ញុំទាំងអស់គ្នាជានិច្ច ។

យើងខ្ញុំទាំងអស់គ្នា សូមលំឱនកាយឧទ្ទិសបួងសួង សូមឱ្យវិញ្ញាណក្ខន្ធរបស់ឯកឧត្តម **សាយ ភូថង** បានចាប់បដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ ។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ សូមក្រុមគ្រួសារនិងញាតិមិត្តនៃសព ឯកឧត្តម **សាយ ភូថង** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ៦ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh